ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
**លេខ ៥២ "អ ក្រ១១"**
ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤២០៨
ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ៣០៩០
ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៣៦៩៨
ចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០២៣

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០២ និង ៣០ នាទី រសៀល នៅសាលសវនាការទី៨ ដោយមានសមាសភាពដូចខាងក្រោម៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤២០៨ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **រ័ត្នមុន្នី** ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅ ភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅ ភូមិ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]រស់" ម្តាយឈ្មោះ [redacted]យុទ្ធ "រស់" នៅលើរ កម្រិតវប្បធម៌ថ្នាក់ទី៣ ជានីតិជន ទោសពីមុនគ្មាន។

**-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៩០ "ជ" ដ.ឃ.ង ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ (ម១)។**

ជាប់ចោទពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវសន្ទរស្ទឹងព្រែកត្នោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] **គឹមហុង** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ មុខរបរ អ្នកនេសាទ ទីកន្លែងកំណើតនៅ ភូមិ[redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន



Scanned with CamScanner

[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ហួរ "រស់" ម្តាយឈ្មោះ [redacted] សុខហៀង "រស់" ប្រពន្ធឈ្មោះ [redacted] ធីម មានកូនចំនួន២នាក់ កម្រិតវប្បធម៌ថ្នាក់ទី៣ ជា នីតិជន ទោសពីមុន គ្មាន ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៨៩ "ជ" ង.ឃ.ង ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ (ម₁) ។

៣-ឈ្មោះ [redacted] **ចាន់នុត ហៅ ប្រុស** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតនៅ ភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួន ស្នាក់នៅ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ វ័ន "ស្លាប់"ម្តាយឈ្មោះ [redacted] ផាន "រស់" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៧ ជា នីតិជន ទោសពីមុន គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៩១ "ជ" ង.ឃ.ង ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ (ម₁) ។

ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មេធាវីការពារសិទ្ធិជនជាប់ចោទលោក [redacted]

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង១៤ និង៤០នាទី កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថខណ្ឌដង្កោ បានចុះល្បាតក្នុងមូលដ្ឋាននៅចំណុច ផ្លូវសន្ធរស្ទឹងព្រែកត្នោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ បានឃើញជនជាប់ចោទឈ្មោះ [redacted] រ័ត្នមុន្នី កំពុងធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ភ្លាមនោះសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួន ជនជាប់ចោទឈ្មោះ [redacted] រ័ត្នមុន្នី ព្រមទាំងដកហូតក្រាមពណ៌សថ្លាចំនួន១កញ្ចប់ ទម្ងន់ 0,១៤ក្រាម ដើម្បីធ្វើការសាកសួរ។ ជនជាប់ចោទឈ្មោះ [redacted] រ័ត្នមុន្នី ទិញគ្រឿងញៀនពីជនជាប់ចោទឈ្មោះ ឈូក ក្នុងតម្លៃ ១០$ (ដប់) ដុល្លារអាមេរិក។ ហើយនៅអំឡុងខែមេសា ឆ្នាំ២០២៣ ជនជាប់ចោទឈ្មោះ [redacted] រ័ត្នមុន្នី, ឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] ចាន់នុត ហៅ ប្រុស បានធ្វើសកម្មភាពផាក់ផ្តួលយកម៉ូតូរបស់ជនរងគ្រោះ មួយគ្រឿង ម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ នៅចំណុច ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] មុន្នីរ័ត្ន បានសហការជាមួយសមត្ថកិច្ច ធ្វើការឃាត់ខ្លួនជន ខ្លួនជនជាប់ចោទឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] ចាន់នុត ហៅ ប្រុស នាំមកមូលដ្ឋានកងរាជអាវុធហត្ថខណ្ឌដង្កោ ដើម្បីធ្វើការសាកសួរតែម្តង។ ហើយសមត្ថកិច្ចបានធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន លើជនជាប់ចោទទាំង៣នាក់ ខាងលើ ជាលទ្ធផល វិជ្ជមាន រួចសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍សំយោគលេខ ១២០/២៣ ក.ប.គ.ញ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤២០៨ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣១២៤ អ.យ.ប ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។



Scanned with CamScanner

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៣០៩០ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ របស់តុលាការដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨ អ.យ.ប ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦៩៣ "ជ" ស.ង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងជំនុំជម្រះលេខ ៣៦៩៨ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] រ័ត្នមុន្នី បានឆ្លើយថា៖ កាលពីខែមេសា ឆ្នាំ២០២៣ ខ្លួនពិតជាបានឆក់គេផ្ដួលយកម៉ូតូ ពិតប្រាកដមែន នៅចំណុច ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ពេលនោះអ្នកចូលរួមធ្វើសកម្មភាពជាមួយខ្លួនមានឈ្មោះ [redacted] គីមហុង និងឈ្មោះ [redacted] ចាន់ឌុត ហៅ។ ខ្លួនឆក់យកម៉ូតូម៉ាក ហុងដាឌ្រីម ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ ពេលយកម៉ូតូនោះបានហើយ យកទៅលក់ចាយប្រាក់អស់ហើយ។ ចំពោះ គ្រឿងញៀនដែលសមត្ថកិច្ចដកហូត គឺខ្លួនបានទិញពីឈ្មោះ [redacted] តម្លៃ ១០ ដុល្លារអាមេរិក ទិញយកមកលក់បន្ត។ ពេលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនបានទំលាក់គ្រឿងញៀនចោលលើផ្លូវ។ ខ្លួនលក់គ្រឿងញៀនបានប្រាំខែហើយ និងចេះប្រើប្រាស់ថ្នាំញៀនដូចគ្នា។

-ជនជាប់ចោទឈ្មោះ [redacted] គីមហុង បានឆ្លើយថា: ខ្លួនពិតជាបានជួយយកម៉ូតូពីឈ្មោះ [redacted] រ័ត្នមុន្នី ទៅលក់ពិតមែន តែពេលនោះពុំមានអ្នកទិញ ខ្លួនក៏យកមកប្រគល់ឲ្យឈ្មោះ ញ៉ែម ពន្លក ដែលត្រូវជាប្អូនរបស់ ញ៉ែម រ័ត្នមុន្នី វិញ។ ខ្លួនបានដឹងដែរថាម៉ូតូនោះគឺវា ([redacted] រ័ត្នមុន្នី) ឆក់គេយកបាន ហើយខ្លួនពិតជាបានចូលរួមឆក់យកម៉ូតូគេជាមួយឈ្មោះ ញ៉ែម រ័ត្នមុន្នី ដែរ។ ខ្លួនធ្លាប់ប្រើថ្នាំញៀនជាមួយឈ្មោះ ញ៉ែម រ័ត្នមុន្នី ពិតមែន។

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌុត បានឆ្លើយថា: នៅដើមឆ្នាំ២០២៣ ខ្លួនតែងតែទៅផ្ទះរបស់ឈ្មោះ [redacted] រ័ត្នមុន្នី ដើម្បីប្រើប្រាស់គ្រឿងញៀន។ ហើយខ្លួនបានឲ្យម៉ូតូទៅឈ្មោះ ហុង ខ្ចីជិះធ្វើសកម្មភាពឆក់យកម៉ូតូគេពិតមែន។ រហូតដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ សមត្ថកិច្ចក៏ឃាត់ខ្លួនពាក់ព័ន្ធនឹងករណីផ្ដល់មធ្យោបាយឲ្យឈ្មោះ [redacted] គីមហុង និងបក្ខពួក ដើម្បីធ្វើសកម្មភាពឆក់គេផ្ដួលយកម៉ូតូ។ ខ្លួនពិតជាបានចូលរួមឆក់យកម៉ូតូគេ ជាមួយឈ្មោះ [redacted] រ័ត្នមុន្នី ពិតមែន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៤២៩៩២/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លាឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៨.៩៣% នៃទម្ងន់សរុប។ មេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១៦០៩ រ.វ.ត/២៣ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣ រួមមាន:



Scanned with CamScanner

ក-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ ញៀម រ័ត្នមុន្នី មានដូចជា:

១-ស្រោមសំបុត្របិទជិត ចំនួន០១ (មួយ) ពណ៌ស ដោយមានសរសេរថា: ក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ ដែលមានតម្រុយសង្ស័យជាសារធាតុញៀនមានទម្ងន់ជាក្រាមសរុប 0,១៤ (សូន្យក្បៀសដប់បួន) ក្រាម ដោយមានស្នាមផ្តិត មេដៃស្តាំរបស់ជនសង្ស័យឈ្មោះ [redacted] រ័ត្នមុនី និងមានចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងមានបោះត្រាមូលរបស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

២-ម៉ូតូ ចំនួន ០៣ (បី) គ្រឿង រួមមាន: ម៉ាក HONDA Dream C125 ពណ៌ខ្មៅ គ្មានផ្លាកលេខ (មិនប្រក្រតី), ម៉ាក VIVA ពណ៌ខ្មៅ ពណ៌ គុណភាពចាស់ ពាក់ផ្លាកលេខ ភ្នំពេញ ១AL-៣០៩២ (មិនប្រក្រតី) និងម៉ាក SUZUKI NEX ពណ៌ក្រហមលាយស ពាក់ផ្លាកលេខ កំពង់ស្ពឺ ១P-៩០៦២

ខ-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted]ចាន់នុត

១-ទូរស័ព្ទដៃ ចំនួន ០១ (មួយ) គ្រឿង ម៉ាក REALME ពណ៌ក្រហម គុណភាពចាស់ មិនដំណើរការ ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន ០១ (មួយ) ពណ៌លឿងទុំ ដោយមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ ម៉ី ចាន់នុត និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។

គ-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ ហួរ គីមហុង មានដូចជា:

១-ទូរស័ព្ទដៃ ចំនួន ០១ (មួយ) គ្រឿង ម៉ាក NOKIA ចុចពិល ពណ៌ខ្មៅ គុណភាពចាស់ មិនដំណើរការ ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន ០១ (មួយ) ពណ៌លឿងទុំ ដោយមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ ហួរ គីមហុង និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។

## សេចក្តីសន្និដ្ឋានម្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងតាមការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងឃើញថា ជនជាប់ចោទបានឆ្លើយសារភាពពីទោសកំហុសរបស់ខ្លួនរួចហើយ ក្នុងនោះជនជាប់ចោទឈ្មោះ [redacted]រ័ត្នមុន្នី បានសារភាពថាខ្លួនបាន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវសន្ធរស្ទឹងព្រែក ត្នោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ លួចមានស្ថានទម្ងន់ទោស (ឆក់យកម៉ូតូ) ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣។ ចំណែកជនជាប់ចោទឈ្មោះ [redacted] គីមហុង និងជនជាប់ចោទឈ្មោះ [redacted] ចាន់នុត បានសារភាពថាពួកខ្លួនបាន លួចមានស្ថានទម្ងន់ទោស (ឆក់យកម៉ូតូ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣។ ដូចនេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់លើជនជាប់ចោទដដែល ប៉ុន្តែតំណាងអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ពិនិត្យលើស្ថានភាពប្រព្រឹត្តល្មើសរបស់ជនជាប់ចោទ ក្នុងពេលធ្វើសកម្មភាពឆក់យកម៉ូតូពីជនរងគ្រោះ គឺជាស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដែលអាចបណ្តាលឲ្យជនរងគ្រោះស្លាប់គ្រប់ពេល ដែលសកម្មភាពធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតមនុស្ស និងសន្តិសុខសង្គមជាខ្លាំង។ តំណាងអយ្យការប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទក្នុងកម្រិតផ្តល់ស្ថានទម្ងន់ទោសដល់ជនជាប់ចោទ។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-លោកមេធាវីការពារសិទ្ធិជនជាប់ចោទបានសន្និដ្ឋានការពារថា៖ តាមការស្តាប់ការសួរដេញដោលក្នុងពេលសវនាការ គឺជនជាប់ចោទបានឆ្លើយសារភាពរួចហើយ ពីទោសកំហុសរបស់ខ្លួន នេះបញ្ជាក់ថាជនជាប់ចោទមានការសហការល្អជាមួយតុលាការ ដូចនេះខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទ ដោយក្តីអនុគ្រោះ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted]វត្ថមុន្នី បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ចាន់នុត បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted]មហុង បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. តុលាការបានទទួលបណ្តឹង តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៦៩៣ "ជ" ង.ង ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វត្ថមុន្នី មកតុលាការដើម្បីជំនុំជម្រះពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវសន្តរស្ទឹងព្រែកឈ្នោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ តាមមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ។ ចំណែកជនជាប់ចោទឈ្មោះ ហួរ គីមហុង និងជនជាប់ចោទឈ្មោះ ម៉ី ចាន់នុត ត្រូវបានសម្រេចបញ្ជូនមកតុលាការដើម្បីជំនុំជម្រះពីបទ៖ លួចមានស្ថានទម្ងន់ទោស (ធាក់យកម៉ូតូ) និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ។

២. ជនជាប់ចោទឈ្មោះ [redacted]វត្ថមុន្នី បានឆ្លើយសារភាពនាពេលសវនាការថា៖ ខ្លួនធាក់យកម៉ូតូម៉ាក ហុងដា ឌ្រីម ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ ពេលយកម៉ូតូនោះបានហើយ យកទៅលក់បានប្រាក់អស់ហើយ។ ចំពោះគ្រឿងញៀនដែលសមត្ថកិច្ចដកហូត គឺខ្លួនបានទិញពីឈ្មោះ ឈូក តម្លៃ ១០ ដុល្លារអាមេរិក ទិញយកមកលក់បន្ត។ ខ្លួនលក់គ្រឿង

គ្រឿងញៀនបានប្រាំខែហើយ និងធ្លាប់ប្រើប្រាស់ថ្នាំញៀនដូចគ្នា។

៣. ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌុត និងឈ្មោះ [redacted] គីមហុង បានឆ្លើយសារភាពនៅពេលសវនាការដូចគ្នាថា: ពួកខ្លួនពិតជាបានចូលរួមឆក់យកម៉ូតូគេជាមួយឈ្មោះ ញ៉ែម រ័ត្នមុន្នី។ ខ្លួនធ្លាប់ប្រើថ្នាំញៀនជាមួយឈ្មោះ [redacted] រ័ត្នមុន្នី ពិតមែន។

៤. តាមចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍សំយោគលេខ ១២០/២៣ ក.ប.គ.ញ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ព្រមទាំងវត្ថុតាងជាគ្រឿងញៀនប្រភេទក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ ដែលមានតម្រុយសង្ស័យជាសារធាតុញៀន មានទម្ងន់ជាក្រាមសរុប ០,១៤ (សូន្យក្បៀសដប់បួន) ក្រាម ដែលបានដកហូតពីជនជាប់ចោទ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] រ័ត្នមុន្នី ពិតជាបានប្រព្រឹត្តអំពើ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវ សារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវសន្ធរស្ទឹងព្រែកត្នោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ និងពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ ប្រាកដមែន។ និងជនជាប់ចោទឈ្មោះ [redacted] គីមហុង និងឈ្មោះ ម៉ី ចាន់ឌុត ពិតជាប្រព្រឹត្តអំពើ: លួចមានស្ថានទម្ងន់ទោស (ឆាក់យកម៉ូតូ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ ប្រាកដមែន។

៥. អំពើរបស់ជនជាប់ចោទ ធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គល សន្តិសុខសង្គម សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ជាអំពើល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦. ជនជាប់ចោទជានីតិជន និងជាជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយ ដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសទេ។ ជននេះមានការពិចារណាយល់ដឹងអំពីផលវិបាកកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៧. សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាព របស់ជនជាប់ចោទ ព្រោះថាជនជាប់ចោទបានសារភាពពីទោសកំហុសរបស់ខ្លួនរួចហើយថាបាន លួចមានស្ថានទម្ងន់ទោស (ឆាក់យកម៉ូតូ) និងជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងតម្កល់បទចោទប្រកាន់ពីបទដដែល ដោយប្តឹងសុំតុលាការសម្រេចផ្តល់ស្ថានទម្ងន់ទោសលើជនជាប់ចោទ ព្រោះស្ថានភាពនៃការប្រព្រឹត្តល្មើសរបស់ជនជាប់ចោទគឺមានសភាពធ្ងន់ធ្ងរ។ តុលាការយល់ឃើញថា មានភាពត្រឹមត្រូវ គប្បីតុលាការលើកមកពិចារណា។

៨. តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៤២៩៩២/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋាន ថា៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លាឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៨.៩៣% នៃ ទម្ងន់សរុប។ មេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

ដូច្នេះគិតរកសារធាតុសុទ្ធ នៃមេតំហ្វេតាមីន (Methamphetamine) ទាំងអស់ដែលដកហូតពីជនជាប់ចោទ គឺមានចំនួន ០,១៤ ក្រាម គុណ ៧៨.៩៣ ភាគរយ ចែកនឹង ១០០ ស្មើ ០.១១ ក្រាម។



Scanned with CamScanner

៩. មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] រ័ត្នមុន្នី ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវសន្តរស្មើងព្រែកឡោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ តាមមាត្រា ៤០ មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] គីមហុង និងជនជាប់ចោទឈ្មោះ [redacted] ចាន់នុត ពីបទ: លួចមានស្ថានទម្ងន់ទោស (ឆក់យកម៉ូតូ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ។

១០. វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១៦០៩ វ.វ.ត/២៣ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២៣ រួមមាន:

ក-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted] រ័ត្នមុន្នី មានដូចជា:

១-ស្រោមសំបុត្របិទជិត ចំនួន០១ (មួយ) ពណ៌ស ដោយមានសរសេរថា: ក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ដែលមានតំរុយសង្ស័យជាសាជាសារធាតុញៀនមានទម្ងន់ជាក្រាមសរុប 0,១៤ (សូន្យក្បៀសដប់បួន) ក្រាម ដោយមានស្នាមផ្តិត មេដៃស្តាំរបស់ជនសង្ស័យឈ្មោះ [redacted] រ័ត្នមុនី និងមានចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងមានបោះត្រាមូលរបស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

២-ម៉ូតូ ចំនួន ០៣ (បី) គ្រឿង រួមមាន: ម៉ាក HONDA Dream C125 ពណ៌ខ្មៅ គ្មានផ្លាកលេខ (មិនប្រក្រតី), ម៉ាក VIVA ពណ៌ខ្មៅ ពណ៌ គុណភាពចាស់ ពាក់ផ្លាកលេខ ភ្នំពេញ ១AL-៣០៩២ (មិនប្រក្រតី) និងម៉ាក SUZUKI NEX ពណ៌ក្រហមលាយស ពាក់ផ្លាកលេខ កំពង់ស្ពឺ ១P-៤០៦២ (មិនប្រក្រតី)។

ត្រូវសម្រេចរឹបអូស តាមមាត្រា ៩៣, ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

ខ-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted] ចាន់នុត

១-ទូរស័ព្ទដៃ ចំនួន ០១ (មួយ) គ្រឿង ម៉ាក REALME ពណ៌ក្រហម គុណភាពចាស់ មិនដំណើរការ ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន ០១ (មួយ) ពណ៌លឿងទុំ ដោយមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ [redacted] ចាន់នុត និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។ ត្រូវសម្រេចរឹបអូស តាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

គ-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted] គីមហុង មានដូចជា:

១-ទូរស័ព្ទដៃ ចំនួន ០១ (មួយ) គ្រឿង ម៉ាក NOKEA ចុចពិល ពណ៌ខ្មៅ គុណភាពចាស់ មិនដំណើរការ ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន ០១ (មួយ) ពណ៌លឿងទុំ ដោយមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ [redacted] គីមហុង និងមានការចូលរមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។ ត្រូវសម្រេចរឹបអូស តាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

## <u>ហេតុដូច្នេះសម្រេច</u>

**១.** ផ្តន្ទាទោសជនជាប់ចោទ៖ ឈ្មោះ [redacted] រ័ត្នមុន្នី ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៥** (ប្រាំ) ឆ្នាំ។



Scanned with CamScanner

ពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ផ្លូវសត្តរស្មីង ព្រែកត្នោត ភូមិព្រែកប្រណាក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៤០** មាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពីបទ: **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៧** ក្រមព្រហ្មទណ្ឌ ។

២. ផ្តន្ទាទោសជនជាប់ចោទ៖

ក-ឈ្មោះ [redacted] **គឹមហុង** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៤ (បួន) ឆ្នាំ**។

ខ-ឈ្មោះ [redacted] **ចាន់ឌុត ហៅ ប្រុស** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៤ (បួន) ឆ្នាំ**។

ពីបទ៖ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ផ្លូវបេតុង ភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **៣៥៣** មាត្រា **៣៥៧** ក្រមព្រហ្មទណ្ឌ និងមាត្រា **៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣. វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ **១៦០៩ រ.ទ.ឥ/២៣** ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២៣ រួមមាន:

ក-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted] **រ័ត្នមុន្នី** មានដូចជា:

១-ស្រោមសំបុត្របិទជិត ចំនួន០១ (មួយ) ពណ៌ស ដោយមានសរសេរថា: ក្រាមពណ៌សថ្លាចំនួន០១កញ្ចប់ ដែលមានគំរុយសង្ស័យជាសាជាសារធាតុញៀនមានទម្ងន់ជាក្រាមសរុប ០,១៤ (សូន្យក្បៀសដប់បួន) ក្រាម ដោយមានស្នាមផ្តិត មេដៃស្តាំរបស់ជនសង្ស័យឈ្មោះ [redacted] រ័ត្នមុនី និងមានចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងមានបោះត្រាមូលរបស់កងរាជអាវុធហត្ថរាជធានីភ្នំពេញ។

២-ម៉ូតូ ចំនួន ០៣ (បី) គ្រឿង រួមមាន: ម៉ាក HONDA Dream C125 ពណ៌ខ្មៅ គ្មានផ្លាកលេខ (មិនប្រក្រតី), ម៉ាក VIVA ពណ៌ខ្មៅ ពណ៌ គុណភាពចាស់ ពាក់ផ្លាកលេខ ភ្នំពេញ ១AL-៣០៩២ (មិនប្រក្រតី) និងម៉ាក SUZUKI NEX ពណ៌ក្រហមលាយស ពាក់ផ្លាកលេខ កំពង់ស្ពឺ ១P-៤០៦២ (មិនប្រក្រតី)។

ត្រូវសម្រេចរឹបអូស តាមមាត្រា *៩៣, ៩៤* នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងតាមមាត្រា **៦២** និងមាត្រា **៦៣** នៃក្រមព្រហ្មទណ្ឌ ។

ខ-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted] **ចាន់ឌុត**

១-ទូរស័ព្ទដៃ ចំនួន ០១ (មួយ) គ្រឿង ម៉ាក REALME ពណ៌ក្រហម គុណភាពចាស់ មិនដំណើរការ ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន ០១ (មួយ) ពណ៌លឿងទុំ ដោយមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ ម៉ី ចាន់ឌុត និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។

ត្រូវសម្រេចរឹបអូស តាមមាត្រា **៦២** និងមាត្រា **៦៣** នៃក្រមព្រហ្មទណ្ឌ ។

គ-វត្ថុចាប់យកដែលដកហូតបានពីជនសង្ស័យឈ្មោះ [redacted] **គឹមហុង** មានដូចជា:



Scanned with CamScanner

១-ទូរស័ព្ទដៃ ចំនួន ០១ (មួយ) គ្រឿង ម៉ាក NOKIA ចុចពិល ពណ៌ខ្មៅ គុណភាពចាស់ មិនដំណើរការ ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន ០១ (មួយ) ពណ៌លឿងទុំ ដោយមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ [redacted] មែហុង និងមានការចូលរមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំង វត្ថុចាប់យក។

ត្រូវសម្រេចរឹបអូស តាមមាត្រា **៦២** និងមាត្រា **៦៣** នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ។

បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។l

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"។

ថ្ងៃ ចន្ទ ១២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner